## *ព័ត៌មានថ្មីៗអំពីគម្រោងទទួលសិស្សត្រឡប់ចូលរៀនវិញតាមចំនួនកំណត់*

*ដូចបានប្រកាសរួចមកហើយ គឺថា ក្រសួងអប់រំ ឡុងប៊ីច នៅតែគ្រោងបន្តការបើកបង្ហាត់មេរៀន និង ការចែកផ្តល់ជំនួយផ្សេងៗភាគច្រើនតាមរយៈ អនឡាញ ក្នុងឆមាសរដូវស្លឹកឈើធ្លាក់ ដែលនឹងបញ្ចប់នៅថ្ងៃទី28 ខែមករា ។ ក្នុងពេលជាមួយគ្នានេះ ក្រសួងអប់រំ LBUSD បន្តការបំពេញមុខងារជាមួយក្រសួងសុខាភិបាលប្រចាំតំបន់ និង រដ្ឋ រួមទាំងក្រសួងអប់រំខោនធី ទៀតផង ដែលពួកគេជួយបង្ហាញអំពីមធ្យោបាយប្រើដំណាក់ការជាបន្តបន្ទាប់សម្រាប់ផ្តល់កម្មវិធីសិក្សានៅក្នុងថ្នាក់ផ្ទាល់តាមចំនួនកំណត់ ដោយផ្តើមគិតគូរមុនគេសម្រាប់ទទួលសិស្សមានភាពពិការ ។*

*ក្នុង ឡូសអ៊ែនជេឡេស ខោនធី គឺសព្វថ្ងៃនេះ សាលារៀនមិនទាន់អាចបើកទ្វារឡើងវិញសម្រាប់ទទួលសិស្សបានទេ ដោយមូលហេតុថា ស្ថាពភាព កូវិដ-១៩ នៅតែស្ថិតក្នុងជាន់ថ្នាក់ជាកម្រិតតឹងរឹងជាងគេ ដែលអាចហៅថា ជាន់ថ្នាក់ជាពណ៌ ស្វាយ - Purple tier ។  បើសិនជា អ៊ិលអេ ខោនធី ធ្លាក់ចុះមកជាន់ថ្នាក់ជាកម្រិតធូរបន្តិចជាបន្ទាប់ទៅ ឬ ជាន់ថ្នាក់ពណ៌ ក្រហម - Red tier ដោយគ្មានភាពប្រែប្រួលអ្វីចំនួន 14 ថ្ងៃ គឺក្រសួងអប់រំ LBUSD នឹងធ្វើការចាត់ចែងទៅកាន់ការបើកសាលារៀនឡើងវិញទៅតាមដំណាក់ការជាបន្តបន្ទាប់ ដែលរាប់បញ្ចូលផងទាំងការប្រើកម្មវិធីរៀនលាយគ្នា (hybrid) ដូចបានរាយបង្ហាញជាគំរូនៅក្នុង* ***គម្រោងសម្រាប់ការបើកសាលារៀន និង សុវត្ថិភាព*** *។*

***ក្បួនណែនាំថ្មី ដែលអាចប្រើសុំលើកលែងពីច្បាប់បាន ដើម្បីបើកសាលារៀនឡើងវិញសម្រាប់ទទួលសិស្សកម្រិតថ្នាក់ទាប***
*ក្រុង ឡុងប៊ីច បានបញ្ចេញក្បួនណែនាំថ្មីនៅក្នុងសប្តាហ៍នេះសម្រាប់សាលារៀនទាំងឡាយណា ដែលមានគោលប្រាថ្នាសុំការលើកលែងពីច្បាប់ ដើម្បីអាចបើកទ្វារឡើងវិញបានសម្រាប់ទទួលសិស្សពីថ្នាក់ transitional kindergarten ទៅដល់ថ្នាក់ទី 2 ។  ការបញ្ចេញក្បួនណែនាំទាំងអស់នេះ គឺមិនមែនមានន័យថា ការសុំលើកលែងពីច្បាប់អាចធ្វើទៅបានភ្លាមៗនោះទេ ។  ត្រូវមានការបង្ហាញដូចការតម្រូវជាតទៅនេះសិន ទើបអាចប្រើស្របតាមក្បួនណែនាំបង្ហាញថ្មីៗនេះបាន ...*

- *សំបុត្រគាំទ្រមកពីសមាគមន៍បុគ្គលិកសាលារៀនទាំងអស់*
- *សំបុត្រគាំទ្រមកពីក្រុមប្រឹក្សាមាតាបិតាទាំងអស់នៅតាមសាលារៀន ដែលបានដាក់ពាក្យ*
- *ការបង្ហាញអោយឃើញថា មានការព្រាងទុកហើយសម្រាប់ធ្វើស្របតាមការតម្រូវផ្នែកសុខភាព និង សុវត្ថិភាព រាប់ទាំងប្រដាប់ប្រដារសម្រាប់ពាក់ប្រើការពារខ្លួនផង*
- *គម្រោងសម្រាប់រាប់បញ្ចូលជាការធ្វើ តែស្ត ឃ្លាំមើលទៅកាន់បុគ្គលិកនៅតាមសាលារៀនទាំងអស់ នៅពេលសាលារៀនកំពុងបើកទ្វារធ្វើការ*
- *កម្មវិធីចាក់ថ្នាំគ្រុនផ្តាសាយ*
- *កម្មវិធីហ្វឹកហ្វឺនអំពីរបៀបឃ្លាំមើលទំនាក់ទំនងរវាងមនុស្សផ្សេងៗ ដែលមានភាពប៉ះពាល់ទៅកាន់បុគ្គលិក*

*នៅពេលក្រសួងអប់រំ LBUSD យល់ថា គេអាចបំពេញតាមការតម្រូវទាំងអស់នេះបានក៏ដោយ ដែលរាប់បញ្ចូលទាំងការតម្រូវផ្នែកសុវត្ថិភាពផង គឺសំខាន់ណាស់ ដែលក្រសួងអប់រំ ឡុងប៊ីច ត្រូវមានសេចក្តីគាំទ្រមកពីសហជីព ហើយនៅពេលឥឡូវនេះ គឺគេកំពុងតែធ្វើការពិគ្រោះជាបន្តបន្ទាប់ជាមួយសមាគមន៍គ្រូបង្រៀន ឡុងប៊ីច និង សមាគមន៍បុគ្គលិកមិនមែនជាគ្រូបង្រៀន ដើម្បីសម្រេចថា តើដល់ពេលណា និង ដល់កម្រិតណា ដែលសាលារៀនប្រចាំតំបន់អាចធ្វើការជ្រើសរើសយកបាន បើសិនជាមានឱកាសល្អសុខសាន្តអាចធ្វើទៅបានមែន ។*

*នៅពេលក្រសួងអប់រំ ឌី ស្ទ្រីគ គិតសម្រេចអំពីអ្វីត្រូវធ្វើជាបន្ត គឺមានបុគ្គលិកក៏កំពុងតែធ្វើការរិះរកញែកមើលផងដែរអំពីលទ្ធផលមកពីការបើកទទួលសិស្សរៀននៅតាមថ្នាក់ផ្ទាល់ ដែលក្រសួងអប់រំ LBUSD កំពុងតែធ្វើនៅតាមសាលារៀន ។ តាំងពីផ្តើមឆ្នាំសិក្សាមក ក្រសួងអប់រំ LBUSD បានបើកផ្តល់ជាកម្មវិធីទទួលផ្ញើក្មេង និង សិស្សថ្នាក់ ព្រីស្គូល ប្រហែល 1600 នាក់នៅតាមហោងស្កាត Kids Club និង មណ្ឌលបណ្តុះបណ្តាលកុមារនៅតាមកន្លែងផ្សេងៗ ។ សូម្បីតែមានការប្រើចំនួនសិស្សតិចនាក់នៅតាមថ្នាក់និមួយៗ និង បានប្រើតាមក្បួនរក្សាសុវត្ថិភាពយ៉ាងត្រឹមត្រូវក៏ដោយ ក៏ក្រសួងអប់រំ ឌី ស្ទ្រីគ នៅតែបានទទួលបទពិសោធន៍រាល់សប្តាហ៍អំពីសេចក្តីត្រូវការបិទកន្លែងឡើងវិញនៅតាមបន្ទប់រៀនខ្លះៗ និង ស្នើសុំអោយសិស្សជាក្រុមតូចៗ និង បុគ្គលិកមួយចំនួននៅផ្ទះសម្រាកជាចំនួនពេល 14 ថ្ងៃ ដោយមូលហេតុមានការចម្លងមេរោគ កូវិដ-១៩ ។ ដោយសំអាងលើបទពិសោធន៍ទាំងអស់នេះ ក៏ក្រសួងអប់រំ ឌី ស្ទ្រីគ ធ្វើការទាំងប្រយ័ត្នប្រយែង ជាពិសេស នៅពេលរដូវគ្រុនផ្តាសាយកំពុងតែចូលមកដល់ ។ សញ្ញារោគគ្រុន និង គ្រុនផ្តាសាយ គឺមានភាពស្រដៀង កូវិដ-១៩ ។ ក្រសួងអប់រំ LBUSD ចង់បានការបន្ថយច្រើនអំពីភាពរំខានដាដដែលៗ ដែលនាំអោយម្តងបើក និង ម្តងបិទថ្នាក់រៀន និង សាលារៀន ។*

## *សម្រាប់មាតាបិតា ដែលមានសិស្សពិការ*

*យោងទៅតាមពត៌មានថ្មីៗមកពីក្បួនណែនាំនៃរដ្ឋ និង ខោនធី ទាក់ទងការស្ទង់វាស់មកលើសិស្សចូលរៀនក្នុងថ្នាក់ផ្ទាល់ ការចែកផ្តល់ជំនួយផ្ទាល់ និង ការសម្រួលកម្មវិធីរៀនពីចម្ងាយសម្រាប់សិស្សជាក្រុមតូចៗ ដែលជាសិស្សមានភាពពិការ និង សិស្សមកពីក្រុមពិសេសផ្សេងៗទៀត គឺក្រសួងអប់រំ LBUSD កំពុងផ្តើមធ្វើការសាកល្បងមើលជាមួយកម្មវិធីជាម្នាក់ទល់ម្នាក់ និង ការស្ទង់វាស់មកលើសិស្សផ្ទាល់នៅតាមមណ្ឌល ព្រីស្គូល ។ បន្ទាប់ពីបានទទួលផលជោគជ័យយ៉ាងពេញលេញជាមួយការស្ទង់វាស់ផ្នែក ព្រីស្គូល ហើយ ក្រសួងអប់រំ LBUSD នឹងបន្តការស្ទង់វាស់ជាបន្ទាប់ទៅទៀតជាមួយសិស្សផ្ទាល់នៅតាមសាលាបឋមសិក្សា មធ្យមសិក្សា វិទ្យាល័យ និង កម្មវិធីរៀនសម្រាប់សិស្សជាមនុស្សធំ ដែលមានភាពពិការ ។*

*នៅពេលក្រុមសិស្សនិមួយៗបានត្រឡប់ចូលរៀនវិញ ក្រសួងអប់រំ LBUSD នឹងធ្វើការជាបន្តយ៉ាងជិតដល់ជាមួយក្រសួងសុខាភិបាល និង សហជីព ដើម្បីបញ្ជាក់អំពីការគោរពតាមទម្រង់ការផ្នែកសុវត្ថិភាពសម្រាប់ការពារដល់បុគ្គលិក និង សិស្សទាំងអស់ ។ ទម្រង់ការទាំងអស់នេះមានជា កម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវផ្នែកសុវត្ថិភាព ការប្រើប្រដាប់ប្រដារពាក់ការពារខ្លួន និង ការធ្វើ តែស្ត យ៉ាងច្បាស់លាស់ ។*

*ពត៌មានជាបន្ថែមនឹងផ្ញើជូនមាតាបិតា នៅពេលក្រសួងអប់រំ ឌី ស្ទ្រីគ បន្តការរៀបជាគម្រោងសម្រាប់បញ្ជូនសិស្សជាក្រុមជម្រើសតូចៗអោយត្រឡប់ចូលរៀនវិញ ។*

*នៅពេលក្រសួងអប់រំ LBUSD បំពេញកិច្ចការជាបន្តទៅមុខ សូមលោកអ្នកទទួលភាពកក់ក្តៅ ដោយជ្រាបថា សុខភាព សុវត្ថិភាព និង សុខុមាលភាពនៃសិស្ស និង បុគ្គលិក គឺនៅតែជាបញ្ហាមុនគេបង្អស់សម្រាប់គិតគូរដោះស្រាយ ។*